Daiichi Life

គម្រោង ELITECare

ទឹកប្រាក់សំណងរហូតដល់ ២លានដុល្លារ

សម្រាប់ការពារហានិភ័យអាយុជីវិត

- **១ទទួលបានទឹកប្រាក់ត្រលប់មកវិញរហូតដល់ ១00%** នៃបុព្វលាភធានារ៉ាប់រង
- ជ្រើសរើសរបៀបបង់បុព្វលាភធានារ៉ាប់រង និងទទួលអត្ថប្រយោជន៍សមស្របតាមគោលបំណង និងលទ្ធភាព

ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៌

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតរបស់ប្រទេសជប៉ុន

ជាមួយប្រតិបត្តិការជាង១២៣ឆ្នាំ

កម្មវត្ថុនៃការធានារ៉ាប់រងរបស់គម្រោង ELITECare

គម្រោង ELITECare គឺជាផលិតផលធានារ៉ាប់រងដែលផ្តល់ជម្រើសដល់អតិថិជនសម្រាប់ការធ្វើផែនការការពារអាជីវកម្ម និងទ្រព្យសម្បត្តិ រៀបចំកេរមរតក និងការចូលនិវត្តន៍ប្រកបដោយភាពស្ងប់ចិត្ត អនាគតកាន់តែប្រសើរ និងសុវត្ថិភាពសម្រាប់គ្រួសារ។

វិសាលភាពនៃការធានារ៉ាប់រង របស់គម្រោងនេះ

គម្រោងនេះគឺធានាអាយុជីវិតអ្នកត្រូវបានធានារ៉ាប់រងទៅលើហានិភ័យមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ ដែលបណ្តាលមកពីហេតុការណ៍ទាំងអស់ (លើកលែងតែ ហេតុការណ៍ទាំងឡាយណាដែលមានចែងនៅក្នុងករណីមិនធានា) ហើយក៏ត្រូវបានធានាជូនលើគម្រោងសន្សំ ដោយមិនគិតពី មរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ផងដែរ។

តើគម្រោង ELITECare ជាអ្វី?

គម្រោង **ELITECare** គឺជាផលិតផលធានារ៉ាប់រងអាយុជីវិតដែលមានការបង់បុព្វលាភធានារ៉ាប់រងរយៈពេលខ្លី ឬតែមួយលើក ហើយទទួលបានការការពាររយៈពេលវែង។ គម្រោងនេះបង្កើតឡើងដើម្បីផ្តល់នូវការការពារខ្ពស់ ដោយធានាបានទាំងទឹកប្រាក់ត្រលប់មកវិញដ៏ឈ្លាសវៃ នៅក្នុងពេលតែមួយ។

លក្ខណៈពិសេស ៣យ៉ាង

ដែលលោកអ្នកត្រូវជ្រើសរើសគម្រោង ELITECare

១ ផ្តល់អត្ថប្រយោជន៍ការពារដ៏ខ្ពស់ (Elite Protection)
ទទួលបានទឹកប្រាក់សំណងរហូតដល់ ២លាន ដុល្លារ អាមេរិក សម្រាប់ការពារហានិភ័យអាយុជីវិត

២ ផ្តល់ទឹកប្រាក់ត្រលប់មកវិញដ៏ឈ្លាសវៃ (Smart Returns)
ទទួលបានទឹកប្រាក់ត្រលប់មកវិញរហូតដល់ ១00% នៃបុព្វលាភធានារ៉ាប់រងដែលត្រូវបង់

៣ ផ្តល់នូវជម្រើសគម្រោងដែលមានភាពបត់បែន (Flexible Plans)
ជ្រើសរើសរបៀបបង់បុព្វលាភធានារ៉ាប់រង និងទទួលអត្ថប្រយោជន៍សមស្របតាមគោលបំណង និងលទ្ធភាព

+សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងទៅកាន់បុគ្គលិកលក់ ឬភ្នាក់ងារធានារ៉ាប់រង

អំពីក្រុមហ៊ុន

ដាយ អ៊ិឈិ ឡាយហ្វ៌ អ៊ីនស្សូរ៉ិនស៍ (ខេមបូឌា) ម.ក ដែលជាក្រុមហ៊ុន**បុត្រសម្ព័ន្ធរបស់ ដាយ អ៊ិឈិ ឡាយហ្វ៌ ហូលឌីង** គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតលានមុខគេមួយរបស់ប្រទេសជប៉ុនជាមួយ**ប្រតិបត្តិការជាង១២៣ឆ្នាំ** នៅលើសាកលលោក។ **ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៌ ហូលឌីង** មានទីស្នាក់ការកណ្តាលនៅ**ទីក្រុងតូក្យូ ប្រទេសជប៉ុន** និងកំពុង**មានប្រតិបត្តិការអាជីវកម្ម នៅ៩ប្រទេស** រួមមាន ប្រទេសជប៉ុន សហរដ្ឋអាមេរិក វៀតណាម តណ្ឌា អូស្ត្រាលី ឥណ្ឌូនេស៊ី កម្ពុជា មីយ៉ាន់ម៉ា និងនូវែលសេឡង់។ ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៌ ហូលឌីង មានគ្រឹះមូលធនដ៏រឹងមាំជាមួយទ្រព្យសម្បត្តិសរុបចំនួន **៤៦៤.៣ ពាន់លានដុល្លារ** និងបុព្វលាភធានារ៉ាប់រងជាង **៤៥.៣ ពាន់លានដុល្លារ** (គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥)។

ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៌ ចាប់ផ្តើមប្រតិបត្តិការអាជីវកម្មនៅកម្ពុជាក្នុងឆ្នាំ២០១៩ និងមានទីស្នាក់ការកណ្តាលស្ថិតនៅរាជធានីភ្នំពេញ និងការិយាល័យសាខានៅខេត្តបាត់ដំបង និងខេត្តសៀមរាប។ ក្រុមហ៊ុនទទួលបាន៣នរង្វាន់ជា **«ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតអន្តរជាតិល្អបំផុតប្រចាំឆ្នាំនៅក្នុងប្រទេសកម្ពុជា»** រយៈពេល២ឆ្នាំជាប់គ្នាគឺឆ្នាំ២០២៣ និង ២០២៤។ ថ្មីៗនេះយើងក៏ទទួលបាន៣នរង្វាន់២បន្ថែមទៀតពី **HR Asia** ក្នុងនាមជា **«ស្ថាប័នការងារល្អបំផុតនៅអាស៊ី»** និង **«៣នរង្វាន់ក្រុមហ៊ុនដែលគិតគូរពីបុគ្គលិកបំផុត»** ប្រចាំឆ្នាំ២០២៤។

គិតត្រឹមខែមករា ឆ្នាំ២០២៥ ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៌ កំពុងផ្តល់ការការពារផ្នែកហិរញ្ញវត្ថុជូនប្រជាជនកម្ពុជាចំនួន **១ម៉ឺន៣៣ន់គ្រួសារ** ជាមួយទំហំទឹកប្រាក់ការពារចំនួន **៩១លានដុល្លារអាមេរិក**។ កន្លងមក ក្រុមហ៊ុនបានទូទាត់សំណង និងអត្ថប្រយោជន៍ផ្សេងៗជូនដល់អតិថិជនចំនួនជាង **១ពាន់២យគ្រួសារ** ក្នុងទំហំទឹកប្រាក់ជាង **៥៩ម៉ឺនដុល្លារអាមេរិក**។

សម្រាប់ព័ត៌មានបន្ថែម
1800 201 202

ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៌ អ៊ីនស្សូរ៉ិនស៍ (ខេមបូឌា) ម.ក
ជាន់ផ្ទាល់ដី ជាន់ទី១ និងជាន់ទី២ អគារសាមគ្គី ផ្លូវលេខ៣១៥ ភូមិ៦
សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

លក្ខណៈទូទៅ	ELITECare
ទឹកប្រាក់ត្រូវបានធានា	ក. ការការពារកម្រិតទី១៖ អប្បបរមា USD ២៥,០០០ ដល់ អតិបរមា USD ៤០០,០០០ ខ. ការការពារកម្រិតទី ២៖ អប្បបរមា USD ២៥,០០០ ដល់ អតិបរមា USD ២០០,០០០
អាយុអ្នកត្រូវបានធានារ៉ាប់រង	ចាប់ពី ១៨ ដល់ ៦០ ឆ្នាំ (ការពារអតិបរមារហូតដល់អាយុ ៧០ឆ្នាំ)
រយៈពេលបណ្ណសន្សាវ៉ាប់រង	៦ ឆ្នាំ ៩ ឆ្នាំ ១២ ឆ្នាំ ឬ១៥ ឆ្នាំ
រយៈពេលបង់បុព្វលាភធានារ៉ាប់រង	ក. គម្រោង ៦ឆ្នាំ មានជម្រើសការបង់បន្ថយខ្លី រយៈពេល ៣ ឆ្នាំ ឬការបង់តែមួយលើក ខ. គម្រោង ៩ ១២ និង១៥ឆ្នាំ មានជម្រើសការបង់បន្ថយខ្លី រយៈពេល ៥ ឆ្នាំ ឬការបង់តែមួយលើក

អត្ថប្រយោជន៍

ជម្រើសអត្ថប្រយោជន៍ការការពារ

ការការពារកម្រិតទី១៖

ក្នុងករណីមរណភាពឬពិការភាពទាំងស្រុងនិងអចិន្ត្រៃយ៍ដែលមិនបណ្តាលពីគ្រោះថ្នាក់ចៃដន្យ នឹងទទួលបាន ២០០% នៃទឹកប្រាក់ត្រូវបានធានា ហើយក្នុងករណីបណ្តាលពីគ្រោះថ្នាក់ចៃដន្យ នឹងទទួលបាន ៤០០% នៃទឹកប្រាក់ត្រូវបានធានា។

ការការពារកម្រិតទី២៖

ក្នុងករណីមរណភាពឬពិការភាពទាំងស្រុងនិងអចិន្ត្រៃយ៍ដែលមិនបណ្តាលពីគ្រោះថ្នាក់ចៃដន្យ នឹងទទួលបាន ៤០០% នៃទឹកប្រាក់ត្រូវបានធានា ហើយក្នុងករណីបណ្តាលពីគ្រោះថ្នាក់ចៃដន្យ នឹងទទួលបាន ៨០០% នៃទឹកប្រាក់ត្រូវបានធានា។

ជម្រើសអត្ថប្រយោជន៍ទឹកប្រាក់ត្រលប់

ជម្រើសទី១៖

អត្ថប្រយោជន៍ទឹកប្រាក់ត្រលប់ ១០០% (ចំនួនទឹកប្រាក់សរុបនៃអត្ថប្រយោជន៍ទឹកប្រាក់ទទួលបានតាមការកំណត់ បូកនិងអត្ថប្រយោជន៍ថ្ងៃផុតកំណត់ស្មើនឹង ១០០% នៃបុព្វលាភធានារ៉ាប់រងត្រូវបង់សរុប)។

ជម្រើសទី២៖

អត្ថប្រយោជន៍ទឹកប្រាក់ត្រលប់ ៧០% (ចំនួនទឹកប្រាក់សរុបនៃអត្ថប្រយោជន៍ទឹកប្រាក់ទទួលបានតាមការកំណត់ បូកនិងអត្ថប្រយោជន៍ថ្ងៃផុតកំណត់ស្មើនឹង ៧០% នៃបុព្វលាភធានារ៉ាប់រងត្រូវបង់សរុប)។

ឧទាហរណ៍៖ លោក តារា មានអាយុ ៤០ឆ្នាំ បានទិញ គម្រោង ELITECare ការការពារកម្រិតទី១ និងជ្រើសរើសអត្ថប្រយោជន៍ទឹកប្រាក់ត្រលប់ ១០០% (ROP)។ លោកបានជ្រើសរើសទឹកប្រាក់ត្រូវបានធានា $២៥,០០០ រយៈពេលបណ្ណសន្សាវ៉ាប់រង ១៥ឆ្នាំ និងរយៈពេលបង់បុព្វលាភធានារ៉ាប់រង ៥ឆ្នាំ។ ដូច្នេះ លោក តារា ត្រូវបង់បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំចំនួន $៣,៦៦៧ ដែលបុព្វលាភធានារ៉ាប់រងត្រូវបង់សរុបរយៈពេល ៥ឆ្នាំ ស្មើនឹង $១៨,៣៣៣។ លោកតារា នឹងទទួលបានអត្ថប្រយោជន៍នៃការធានារ៉ាប់រងនេះមានដូចតទៅ៖

លោកអ្នកអាចធ្វើការបង់បុព្វលាភតាមមធ្យោបាយដូចជា៖ ប្រចាំខែ ឬ ប្រចាំត្រីមាស ឬ ប្រចាំឆមាស ឬ ប្រចាំឆ្នាំ ឬ បង់តែមួយលើក។

លោកអ្នកអាចធ្វើការបង់បុព្វលាភតាមវិធីសាស្ត្រដូចជា៖ មូលប្បទានបត្រ ឬ ការផ្ទេរប្រាក់ចូលគណនីធនាគាររបស់ក្រុមហ៊ុន ដាយ អ៊ិលី ឡាយហ្វ៌ អ៊ីនសួរ៉ិនស៍ (ខេមបូឌា) ម.ក ឬ បញ្ជាបង់ប្រាក់អចិន្ត្រៃយ៍ ឬ ផ្សេងៗ។

ចំណាំ៖ ប្រសិនបើខកខានមិនបានបង់បុព្វលាភធានារ៉ាប់រងតាមកាលបរិច្ឆេទកំណត់ត្រូវបង់បុព្វលាភរ៉ាប់រង ក្រុមហ៊ុន ដាយ អ៊ិលី ឡាយហ្វ៌ នឹងផ្តល់រយៈពេលអនុគ្រោះ និងបន្តការធានាចំនួន ៣០ថ្ងៃ ជូនដល់អតិថិជនដើម្បីបន្តបង់បុព្វលាភធានារ៉ាប់រងដែលនៅសេសសល់ ក្នុងករណីម្ចាស់បណ្ណសន្សារ៉ាប់រងជ្រើសរើសការបង់បន្ថយខ្លី។ អតិថិជនគ្រាន់តែធ្វើការបង់បុព្វលាភឡើងវិញតែប៉ុណ្ណោះដើម្បីបន្តសុពលភាពឡើងវិញ។

ក្នុងករណីម្ចាស់បណ្ណសន្សារ៉ាប់រងនៅបន្តខកខានបង់បុព្វលាភធានារ៉ាប់រងលើសពីរយៈពេលអនុគ្រោះ ៣០ថ្ងៃ ក្រុមហ៊ុននឹងមិនបន្តការធានានោះទេ ហើយម្ចាស់បណ្ណសន្សារ៉ាប់រងត្រូវស្នើសុំបន្តសុពលភាពមកកាន់ក្រុមហ៊ុន ដាយ អ៊ិលី ឡាយហ្វ៌ ដើម្បីទទួលបានការការពារឡើងវិញនៅក្នុងរយៈពេលយ៉ាងយូរបំផុត ២ (ពីរ)ឆ្នាំ ដោយរាប់បញ្ចូលទាំងរយៈពេលអនុគ្រោះ ៣០ថ្ងៃ។

***ករណីដែលមិនធានា**

១. ករណីដែលមិនធានា ក្នុងករណីទទួលមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ ដែលមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ

ក្រុមហ៊ុន ដាយ អ៊ិលី ឡាយហ្វ៌ នឹងមិនទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រងនៃបណ្ណសន្សារ៉ាប់រងនេះឡើយ ប្រសិនបើមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រង កើតឡើងដោយសារមូលហេតុណាមួយ ទោះបីដោយធ្លាស់ ឬដោយប្រយោលក្តី ក្នុងចំណោមហេតុការណ៍ដូចខាងក្រោម៖

ក. ធ្វើអត្តឃាតក្នុងរយៈពេល ២ (ពីរ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្សារ៉ាប់រង ឬកាលបរិច្ឆេទការចាប់ផ្តើមមានសុពលភាពនៃការបន្ទុសពុលភាពឡើងវិញ ដោយមិនគិតអំពីស្ថានភាពផ្លូវចិត្តរបស់អ្នកត្រូវបានធានារ៉ាប់រង ដែលយកកាលបរិច្ឆេទចុងក្រោយគេ (អនុវត្តចំពោះតែករណីមរណភាពតែប៉ុណ្ណោះ)។ ឬ

ខ. ការឆ្លងមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺដែលពាក់ព័ន្ធនឹងជំងឺអេដស៍ ឬ

គ. ការប្រើប្រាស់ សារធាតុញៀន ឬគ្រឿងញៀនខុសច្បាប់ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹងដូចមានចែងក្នុងច្បាប់និងបញ្ញត្តិជាធរមាន។

ឃ. បទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្តដោយម្ចាស់បណ្ណសន្សារ៉ាប់រង ឬ អ្នកត្រូវបានធានារ៉ាប់រង ឬ អ្នកទទួលផល។

ង. ការប្រឈមនឹងគ្រោះថ្នាក់ដោយចេតនា ការប៉ុនប៉ងធ្វើអត្តឃាត ការប៉ុនប៉ងធ្វើបាបខ្លួនឯង ឬបង្ករបួសលើខ្លួនឯងដោយចេតនា ទោះបីស្ថិតនៅក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ (អនុវត្តចំពោះតែករណីពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍តែប៉ុណ្ណោះ) ឬ

ច. ពិការភាពដែលកើតឡើងមុនពេលកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្សារ៉ាប់រង ឬ កាលបរិច្ឆេទបន្តសុពលភាពឡើងវិញ (អនុវត្តចំពោះតែករណីពិការភាពទាំងស្រុងនិងអចិន្ត្រៃយ៍តែប៉ុណ្ណោះ)។

២. ករណីដែលមិនធានា ក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ បណ្តាលពីគ្រោះថ្នាក់ចៃដន្យ

បន្ថែមលើប្រការ ១ ក្រុមហ៊ុនដាយ អ៊ិលី ឡាយហ្វ៌ នឹងមិនទូទាត់អត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យស្របតាមបណ្ណសន្សារ៉ាប់រងនេះឡើយ ប្រសិនបើមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រងកើតឡើង ដោយសារគ្រោះថ្នាក់ចៃដន្យណាមួយ ទោះបីដោយធ្លាស់ ឬដោយប្រយោលក្តីក្នុងចំណោមហេតុការណ៍ដូចខាងក្រោម៖

ក. សង្គ្រាម (ប្រកាស ឬមិនបានប្រកាស) ភាពចលាចល ឬ ប្រតិបត្តិការសង្គ្រាមស្នាមស៊ីវិល ការរ៉ះចោរ ឬ ភាពវឹកវរក្នុងប្រទេស ឬ កុបកម្ម ឬ ក្ងកក្ងឹម ឬ

ខ. គ្រឿងផ្ទុះ ឬវិទ្យុសកម្មដោយសារតែអាវុធឆបករណ៍គ្រឿងផ្ទុះកែច្នៃ នុយក្លេអ៊ែរ ឬអាវុធគីមី ឬ

គ. ការប្រើប្រាស់ សារធាតុញៀន ឬគ្រឿងញៀនខុសច្បាប់ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹងដូចមានចែងក្នុងច្បាប់និងបញ្ញត្តិជាធរមាន។

ឃ. ការជិះធាមួយ ឬបើកបរក្នុងការប្រណាំង ឬកីឬវិធ្លាជីវៈណាមួយ ឬសកម្មភាពត្រមុជទឹក ពាក់ព័ន្ធនឹងការប្រើប្រាស់ឧបករណ៍ដកដង្ហើម ឬ

ង. សកម្មភាពហោះហើរ ឬអាកាសចរណ៍ទានា លើកលែងតែការធ្វើដំណើរបង់ប្រាក់តាមយន្តហោះដែល មានអាជ្ញាប័ណ្ណត្រឹមត្រូវ មានលក្ខណៈពាណិជ្ជកម្ម និងមានកាលវិភាគនៃការធ្វើដំណើរ ឬ

ច. ការឆ្លងមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺដែលពាក់ព័ន្ធនឹងជំងឺអេដស៍ ឬ

ឆ. ការប្រឈមនឹងគ្រោះថ្នាក់ដោយចេតនា ការប៉ុនប៉ងធ្វើបាបខ្លួនឯង ឬបង្ករបួសលើខ្លួនឯងដោយចេតនា ទោះបីស្ថិតនៅក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ក៏ដោយ (អនុវត្តចំពោះតែករណីពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍តែប៉ុណ្ណោះ) ឬ

ជ. ពិការភាពដែលកើតឡើងមុនពេលកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្សារ៉ាប់រង ឬ កាលបរិច្ឆេទបន្តសុពលភាពឡើងវិញ(អនុវត្តចំពោះតែករណីពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍តែប៉ុណ្ណោះ) ។

ករណីសុខសប្បាយ



ករណីមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍



ចំណាំ៖ អត្ថប្រយោជន៍ទឹកប្រាក់ទទួលបានតាមការកំណត់ និងអត្ថប្រយោជន៍ថ្ងៃផុតកំណត់នៅតែផ្តល់ជូនទោះបីមានករណីមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ក៏ដោយគ្មី។